~១~

# គួភម្ហ!

ឆ្នាំ ១៩៩៨ ...

សត្វសេកដ៏ល្អមួយ ស្ថិតក្នុងទ្រុងក្បាច់យ៉ាងស្អាតប្រណិត កំពុងលោតចុះ លោតឡើងយ៉ាងសប្បាយ ចឹកចំណីដែលម្ចាស់កំពុងបញ្ចុក លោកជេនជាថៅកែក្រុមហ៊ុនជំនួញមានមុខមាត់ណាស់ក្នុងក្រុងភ្នំពេញនាបច្ចុប្បន្ននេះ ភាគហ៊ុនរបស់លោកមានជាច្រើនកន្លែងហើយពេលទំនេររបស់លោក គឺនៅជាមួយសេកមួយនេះព្រោះលោកស្រលាញ់វាខ្លាំងណាស់ លោកជេនបង្ហាត់វានិយាយរាល់ថ្ងៃនៅខ្ទួសលំហែមិនដែលខានទេ! លោកជ្រលម្ទេសឱយសេក

-នំ១ បើចង់ស៊ី ត្រូវថាតាមយើង ហកនិយាយទៅ "លោកជេនអស្ចារ្យ១"

សត្វសេកចំណាប់ លោតចុះលោតឡើងស្រែក

-លោកជេនអស្ចារ្យ១

រួចវាសើចហាស់១! ត្រាប់តាមលោកជេនដែលកំពុងសើចសប្បាយជា

មួយសត្វដ៏ចំណាប់របស់គាត់ ខណៈនោះបុរសរូបសង្ហាម្នាក់ស្ថិតក្នុងវ័យប្រហែល ២៦.២៧ឆ្នាំ មាឌមាំមួនសម្បុរសជ្រះ ច្រមុះស្រួចដូចកូនកាត់ មុខមានសំរស់ តែកំពុងក្រញ៉ូវហាក់ដូចជាមិនសប្បាយចិត្តរឿងអ្វីមួយ អ្នកកំលោះនេះគឺជាកូនប្រុសទោលរបស់លោកជេន ឈ្មោះ វ៉ាជីន គ្រាន់តែចូលមកដល់ខ្ញូសលំហែភ្លាម គេអុកបង្គុយលើកៅអីក្បាច់ក្បែរនោះរអ៊ូរទាំបណ្ដើរ

-គួរឱយធុញទ្រាន់មែនទែន!

លោកជេនដៀងភ្នែកមើលមុខកូន

-យ៉ាងម៉េចនឹង? មុខម៉ូម៉ៅពីចំងាយតែម្ដង! មានរឿងស្អីទៀតហើយ?

ជីនជ្រួញចិញ្ចើម

-គឺអនាគតកូនប្រសារប៉ានឹងណា! សំពត់ក្នុងផ្ទត់ដែលប៉ាពេញចិត្តនោះ វាពិបាកមែនទែន! កូនមិនចង់ជ្រើសរើសចិត្តឯងទេ ព្រោះគោរពតាមបំណងប៉ា! តែក្បួនច្បាប់នោះវាជ្រុលហួស ជាគូដណ្ដឹងនឹងគ្នាទៅហើយ គ្រាន់តែសុំដើរលេងជាមួយគ្នាឱយស្គាល់ចិត្តថ្លើម ស្គាល់និស្ស័យគ្នាខ្លះក៏មិនបាន! បែបនេះដូចជាមិនត្រូវធាតុគ្នាសោះ!

លោកជេនហួសចិត្តដើរមកអង្គុយក្បែរកូនទះស្មាជីនតិចៗ

-ស្រីដែលកូនអាចហៅទៅដើរលេងស្មើណាក៏បាននោះ គេមិនហៅថាប្រពន្ធទេជីន! កូនស្រីដែលទទួលការអប់រំល្អ រស់ក្នុងពូជអំបូរល្អគឺ ទាល់តែបែបនេះ!

អ្នកកំលោះធ្វើមុនជូរ

-លោកប៉ាកូនដឹងហើយ ថារកប្រពន្ធត្រូវរើសចរិយានោះ! តែនេះជាកាលសម័យដើរទៅមុខណាប៉ា! កូនចង់បានប្រពន្ធដែលចេះយល់ចិត្ត ចេះថ្នាក់ថ្នមចិត្តគ្នា បើរវល់តែនឹងទូនចេញជំរាបលា ចូលជំរាបសួរបែបនេះ ដាច់ខ្យល់បាត់ទៅហើយ!

លោកជេនសំឡក់កូនពីក្នុងវ៉ែនតាមីញ៉ូបភ្នែកឡើងសស្កាស

-រឿងដើរនោះប្រាកដជាទៅមុខហើយ! តែមុននឹងបោះជំហ៊ាន ត្រូវរក្សាជំហរច្បាស់លាស់ប្រាកដប្រជាតាមគន្លងប្រពៃណីរបស់ចាស់ទុំ ទើបវាមិនធ្លាក់ក្រឡុកផុងរណ្ដៅ! បើស្រីដូចម៉ារីហើយកូនទាស់ចិត្ត! តើនារីបែបណាទៅដែលពេញភ្នែកឯងនោះ?

ជីនញាក់ស្មា

-ប្រហែលជា...ទាល់តែស្អាត! ឆ្លាតវៃ! រហ័សរហួន ហើយចេះយល់អធ្យាស្រ័យប្ដី និង ម្ចិកម៉ូក់បន្តិចបន្តួចខ្លះទៅ កុំធ្ងឹងៗដូចម៉ារីពេកណាលោកប៉ា

លោកជេនក្រវីក្បាល់ទ្រង់ហួសចិត្តនឹងកូនប្រុស

-តែប៉ាមិនអនុញ្ញាត្តិឱយឯងធ្វើអ្វីស្រេចនឹងចិត្តទេ!

អ្នកកំលោះងើបឈរឡើងសំដែងអាការៈធុញថប់

-ខ្ញុំដឹងថាទោះយ៉ាងណាក៏ប៉ានៅតែពេញចិត្តម៉ារីដែរ! ខ្ញុំខ្ជិលប្រកែកជាមួយប៉ាណាស់ តែរៀបការរួច ពួកខ្ញុំអាចរស់នៅចុះសំរុងគ្នាបាន ឬ មិនបាននោះកូនមិនធានាទេ!

និយាយចប់គេដើរចូលផ្ទះបាត់ លោកជីនធ្វើមុខស្មើតាមមើលកូនព្រោះ

លោកមិនសប្បាយចិត្តទេ ដែលកូនប្រុសគិតបែបនេះ ព្រោះលោកមឿនឪពុកម៉ារីជាមិត្តជិតស្និតបំផុតរបស់លោក បើនិយាយពីទ្រព្យសម្បត្តិ គ្រួសារទាំងពីរក៏ស័ក្តិសមនិងគ្នាណាស់ លោកមឿនជាប្រធានកាំសាបប្រចាំកំពង់ផែទាំងមូល ឯម៉ារីនាងជាពេទ្យផ្នែកជម្ងឺទូទៅនៅមន្ទីរពេទ្យព្រះកុសុមៈ នាងធ្វើការបណ្ដើររៀនបន្ថែមបណ្ដើរយកសញ្ញាប័ត្រវេជ្ជបណ្ឌិត រូបនាងស្រស់ស្អាត ចរិយាទន់ភ្លន់ គ្រាន់តែបញ្ហាធំគឺ វ៉ាជីនមិនចូលចិត្តនារី ដែលរម្យទម្យពេកដូចម៉ារីទៅវិញ ។ ទោះបីជាយ៉ាងណានេះក្ដី លោកជេនមិនព្រមឱយកូនប្រុសរបស់លោក ធ្វើតាមទំនើងចិត្តឡើយ ពិតមែនតែលោកមានកូនប្រុសតែមួយគត់ តែលោកបានអប់រំគេតាំងពីតូចមក ដោយម៉ឺងម៉ាត់ និង ម៉តចត់មិនថ្នមទំរើសគេដូចកូនតែមួយរបស់គ្រួសារអ្នកមានខ្លះទៀតនោះឡើយ ។

លោកជេន ប្រឡែងលេងជាមួយសេកចេះនិយាយរបស់លោកមួយសន្ទុះទើបផ្លាស់សំលៀកបំពាក់ចេញទៅក្រុមហ៊ុនរបស់លោក ព្រោះមានការណាត់ជួបគ្នាជាមួយអ្នកមានភាគហ៊ុនជាមួយគ្នា ។នៅក្នុងបន្ទប់ផ្ទាល់របស់លោកជេន ស្មៀនជំនិតរបស់លោកឈ្មោះ សាន ដែលមានវ័យស្រករនិងលោកដែរកំពុងប្រមូលបញ្ជីបូកសរុបមកបង្ហាញជូនលោកជេន និង លោកយ៉េតដែលរួមភាគហ៊ុនជាមួយគ្នាពិនិត្យមើល

-លោកប្រធាន ក្រុមហ៊ុនសំណង់របស់យើងមានដំណើរការល្អធម្មតា ព្រោះស័ង្កសី ស៊ីម៉ង់ត៍នៅនឹងតម្លៃ តែទូកបង្ការបស់យើងនៅកំពង់សោម ទិញមិនបានសោះ ចេញប៉ុន្មានជើងខាតតែថ្លៃប្រេង និង ការចាយវាយរហូត

លោកយ៉េត បើកសៀវភៅបញ្ជីមើលទាំងទឹកមុខមិនសប្បាយចិត្ត

-ឆ្នាំនេះម៉េចក៏គ្មានប្រាក់ចំណូលសោះអញ្ចឹង? ទូក២ , ៣ខាតព្រមគ្នាយ៉ាងនេះ ធ្វើម៉េចទៅ?

លោកជេនគ្រវីក្បាលតិចៗ

-ទោះជាយ៉េតឯងជាប់រវល់មិនបានចុះភ្ជាប់ទូកធំ តែខ្ញុំរកស៊ីស្មោះត្រង់ណាស់ យើងរកស៊ីជាមួយគ្នាយូរមកហើយ! រាប់អានគ្នាក៏ច្រើនឆ្នាំ ខ្ញុំមិនប្រើវិធីកេងប្រវ័ញ្ចន៍លើគ្នាឯងនោះទេ!

លោកយ៉េត ដៀងភ្នែកមើលមុខស្មៀនសាន រួចតបបញ្ចិតបញ្ចៀង

-ខ្ញុំមិនចង់ចោទថាលោកកេងប្រវ័ញ្ចន៍ទេ តែលោកទុកចិត្តអ្នកក្រោមបង្គាប់ពេក ជួនកាលនាំឱយខាតទាំងដើមទុនរបស់ខ្ញុំទៀតផង មើលទៅបើខាតរហូតយ៉ាងនេះទាល់តែខ្ញុំរកកូនក្មួយខ្ញុំឱយមកជួយមើលបញ្ជីចុះសមុទ្រហើយ!

ស្មៀនសានលួចសំឡក់លោកយ៉េតមុខស្មើ ព្រោះវាមានប៉ះពាល់ដល់ខ្លួនគាត់ លោកជេនតបបែបហើ

-យើងដាក់ហ៊ុនរួមគ្នា ត្រូវតែធ្វើអញ្ចឹងហើយកន្លងមកលោកគ្មានអ្នកណាអាចមកមើលការងារនេះបាន ទើបខ្ញុំចេះតែរ៉ាប់រងម្នាក់ឯងទៅ!

ពិនិត្យបញ្ជីរួចរាល់លោកយ៉េតនិងលោកជេនក៏បែកផ្លូវគ្នា ព្រោះលោកយ៉េតចង់ហួសទៅមើលហាងថតរូបរបស់លោកមួយកន្លែងទៀត ។

ល្ងាចនេះពេលចេញពីក្រុមហ៊ុនទៅដល់ផ្ទះ លោកស្មៀនសាន មិនសូវសប្បាយចិត្តសោះ ព្រោះនៅតែនឹកឃើញអន់ចិត្តនិងសំដីលោកយ៉េត ដែលមាន

ន័យចង់និយាយថា គាត់ជាអ្នកកិបកេងលុយកាក់ក្រុមហ៊ុន។ គាត់កំពុងរើក្បាលបញ្ជីមុនៗមកពិនិត្យនិងរៀបចំឱ្យបានស្រួលម៉តចត់ នៅតុការងាររបស់គាត់ជាប់មាត់បង្អួចបន្ទប់សាឡុង។ វ៉ាជីនបើកឡានចូលមកដល់ល្មម អ្នកកំលោះចតឡាននៅទីធ្លាក្បែរសួនច្បារ ផ្ទះរបស់លោកសានជាផ្ទះវីឡាកាត់ តូចល្មមតែរៀបចំស្អាតណាស់ ជាពិសេសគឺផ្កាណាត្រីដែលក្រអូបបំផុតនៅពេលយប់មានជាច្រើនផើងតំរៀបយ៉ាងមានរបៀប ផ្ការីកលាស់ល្អបញ្ជាក់ថា ម្ចាស់គេហដ្ឋាននេះស្រឡាញ់ផ្កាណាស់។ វ៉ាជីនមិនធ្លាប់មកផ្ទះលោកសានទេ ទើបតែថ្ងៃនេះគេត្រូវឪពុកប្រគល់កិច្ចការរៀបចំសណ្ឋាគារមាត់ទន្លេមួយ ដោយមានលោកសានជាអ្នកជួយចាត់ចែងជាមួយជីន លោកចង់ឱយជីនរៀនទទួលខុសត្រូវការងារជំនួសលោកជាបណ្តើរៗ ព្រោះបន្តិចទៀតគេរៀបការត្រូវទទួលរងភារៈជាមេគ្រួសារទាំងស្រុងហើយ។ មាណពសង្ហាឃ្លរកាតាបធ្វើការចូលទៅក្នុងផ្ទះលោកសានទ្រង់ឆ្ងល់ ព្រោះឃើញផ្ទះលោកដូចជាស្ងាត់ពេក។ លោកសានក្រលេកឃើញជីន ស្ទុះចេញមកទទួលត្រឹមមាត់ទ្វារដោយរាក់ទាក់

-អញ្ជើញចូលលោកក្មួយ! លោកប្រធានមិនអញ្ជើញមកជាមួយទេឬ?

វ៉ាជីនចូលទៅអង្គុយនៅតុសាឡុងជាមួយលោកសាន

-បាទ! ប៉ាប្រគល់ភារៈរៀបចំសណ្ឋាគារថ្មីរបស់យើងនេះឱយខ្ញុំជាមួយលោកពូជួយចាត់ចែងគ្នា លោកប៉ាមិនលូកដៃជាមួយទេ! ប្រហែលជាគាត់ចង់សាកល្បងខ្ញុំហើយ

លោកសានសើចញឹមៗ

-បន្តិចទៀតលោកក្មួយត្រូវរ៉ាប់រងកិច្ចការទាំងអស់ជំនួសលោកប្រធាន គួរតែចាប់ផ្តើមពីឥឡូវនេះហើយ!

ជីនញញឹមមិនឆ្លើយ គេយកប្លង់រៀបចំតុបតែងសណ្ឋាគារ មកពិគ្រោះជាមួយលោកសាន តើត្រូវការអ្វីខ្លះ ថវិកាប៉ុន្មានដើម្បីរៀបចំអោយបានទំនើប។

ណាត្រី! បុត្រីតែមួយរបស់លោកសានកំពុងកាន់ទុយោទឹក ដេញបាញ់ដាក់កូនឆ្កែតឿស្អាតទ្រលុកៗរបស់នាង។ វ័យ២២ឆ្នាំរបស់ណាត្រីប្រៀបដូចផ្កាកំពុងរីកស្ទុះស្គាយមិនខុសពីផ្កាណាត្រី នៅក្នុងសួនរបស់នាងឡើយ... រីកស្រស់ល្អ... ផូរផង់ ភ្លឺថ្លាដូចស្រទាប់ផ្កានាអរុណោទ័យ នាងកាត់សក់រ៉ាល់ខ្លីក្តោបបង្ហាញវង្វង់ភ័ក្ត្រមូលក្រឡង់សមសោភា។

ស្រស់ស្រី ដេញបាញ់ទឹកលាងជំរះឆ្កែរបស់នាងទាំងសើចកក្អឹក

-គគ្រិចណាស់សំឡី! ចង់រត់ទៅណា? ស្មានថារួចខ្លួនឬ?

នាងក្រមុំបាញ់មិនចំឆ្កែ ទៅត្រូវឯឡានរបស់ជីនទទឹកស្រម៉ក នាងភ្ញាក់ព្រើត ខំយកដៃខ្ទប់ទុយោទឹកទាំងបើកភ្នែកធំៗ ពេលនោះជីន និង លោកសានបណ្តើរគ្នាមកដល់ឡានល្មម មាណវីបោះទុយោទឹកចោល រត់ទៅពួនក្រោយឡាន អ្នកកំលោះក្រឡេកឃើញឡានអ្នក ដែលទើបនឹងលាងយ៉ាងស្អាតត្រូវប្រឡាក់ខ្ទេចដូច្នេះ ក៏ធ្វើភ្នែកស្លឹស្ទុះទៅអើតមើលឡាន

-អ៎ា! ឡានរបស់ខ្ញុំ ម៉េចក៏ប្រឡាក់អស់អញ្ចឹង?

ណាត្រី លបៗដើរវៀងក្រោយឡានបំរុងរកផ្លូវគេច លោកសានធ្វើមុខមឹងម៉ាំង

-ទេ! ផ្ទះរបស់ពូគ្មានក្មេងឯណាហ៊ានចូលមកលេងបែបនេះទេ!

លោកដើរទៅអើតមើល ជួនជាណារីកំពុងដើរគេចអោន១ លប១ពីម្ខាងមក ក៏ជល់ជាមួយឪពុកម៉ាំង! លោកសានភ្ញាក់ក្រញ៉ាង

-អេ! ណារី កូនឯងកំពុងធ្វើស្អីនឹង?

ឆោមស្រស់ងើបឈរត្រង់ខ្លួន ត្រដុះដៃសើចអ៊ឹមអៀន

-ចា៎! កូនកំពុងធ្វើឱយប្រឡាក់ឡានលោកម្នាក់នោះហ្នំ!

ជីនមើលមុខនាងភ្លឹក ព្រោះនាងស្រស់ស្អាត ហើយស្លៀកពាក់ទាន់សម័យណាស់ ណារីងាកមកសើចដាក់ជីនវាចារួសរាយតាមចរិតមិនចេះអៀនប្រៀនរបស់នាង

-សុំទោសលោក! ខ្ញុំគ្មានចេតនាធ្វើឱយឡានរបស់លោកប្រឡាក់ទេ បំរុងគេចទៅឱយបាត់កុំឱយម្ចាស់គេដឹងដែរ! តែគេចមិនទាន់ !

ជីនអស់សំណើច គេហាក់ដូចមានអារម្មណ៍ពេញចិត្តនឹងភាពរួសរាយរបស់នាងក្រមុំខ្លាំងណាស់

-អ្នកនាង និយាយត្រង់១ល្អណាស់ហ្នំ!

លោកសានសើចញញឹម១ណែនាំឱយស្គាល់គ្នា

-នេះណារីកូនស្រីរបស់ពូ ចរិតពិបាកបន្តិច នឹកឃើញយ៉ាងណាគឺនិយាយយ៉ាងនោះហើយ!

អ្នកកំលោះញញឹមតបវិញ

-តែខ្ញុំថាបែបនេះល្អជាង ដែលរម្យទម្យសំបកក្រៅ ហើយវៀចវេក្នុងចិត្តណាលោកពូ!

ណារីញញឹមដាក់ជីនយ៉ាងស្រស់

-អរគុណដែលលោកមិនប្រកាន់នឹងរឿងប្រឡាក់ឡាន

-ឡានប្រឡាក់អាចលាងជ្រះទេតើអ្នកនាង!

នៅក្នុងសួនច្បារ កំលោះម្នាក់កំពុងធ្វើស្មៅផ្កាបណ្តើរ អើតមើលមករ៉ាជីន និង ណារីជជែកគ្នាបណ្តើរ។ គេជាបុរសម្នាក់មានរូបរាងសង្ហាណាស់ តែវត្ថែករបស់គេស្រោបដោយទឹកដម ស្រទន់ភ្លឺថ្លា រង្វង់មុខមានអំណោយទានសម្បុរសណ្តែកបាយ ចំជាតួអង្គប្រុសខ្មែរ ទោះជាសំលៀកបំពាក់គេចាស់ពក្អក់ តែមិនអាចបិតបាំងភាពសង្ហារបស់គេបានឡើយ ។ មាណពរូបស្អាតម្នាក់នេះឈ្មោះ យុត្តិកា ជាក្មួយសាច់ឆ្ងាយម្នាក់របស់លោកសាន ហើយមកសុំស្នាក់នៅផ្ទះរបស់លោកដើម្បីរៀនសូត្រ។ យុត្តិកាឃើញជីនតាមសំឡឹងណារីមិនដាក់ភ្នែក ទឹកមុខគេហាក់ដូចជាស្រយុតស្រយង់ ស្រពាប់ស្រពោនភ្លាម។ ជាធម្មតាទេ កំលោះក្រមុំដែលរស់នៅក្បែរគ្នារាល់ថ្ងៃមិនលែងមានមនោសញ្ចេតនាអូសទាញដោយ មិនដឹងខ្លួនឡើយ។ ពេលក្រឡេកមើលទៅឃើញឡានដ៏ទំនើបរបស់លោកជីន យុត្តិកាដកដង្ហើមធំ ឈ្ងោកធ្វើការងាររបស់ខ្លួនបន្តទៀត លែងហ៊ានងាកមើល ពួកគេ! ។ ណារីឃើញជីនមើលមុខនាងពេក ក៏គេចចូលក្នុងវិញយ៉ាងលឿន។ ចំណែកលោកសានបែរជាលួចញញឹមដោយក្តីពេញចិត្តទៅវិញ ព្រោះលោកសំឡឹងឃើញជីនជាកូនប្រុសតែមួយ ដែលត្រូវគ្រងមតកជាច្រើន ហើយលោកជាជំនិតរបស់លោកជេន បានដឹងរឿងរ៉ាវទាំងអស់ក្នុងគ្រួសារនេះ

ថា ជីនមិនបានពេញចិត្តនឹងម៉ារីទេ បើសិនជាគេពេញចិត្តណាត្រីវិញនោះលោកគិតថាជាលាភធំតែម្តង។ លោកសាន និង រ៉ាជីននាំគ្នាឡើងឡានចេញទៅមើលសណ្ឋាគារថ្មីជាមួយគ្នា។

យុត្តិកាធ្វើស្មៅសួនច្បារទាល់តែរួចបែកញើសជោគខ្លួន មីងនាតជាមេផ្ទះចំណាស់នៅក្នុងគ្រួសារនេះចេញមកស្រែកហៅ

-អ៊ី តិកា លួមរកងូតទឹកហើយ អ្នកនាងនៅចាំញុំាបាយជុំគ្នា

-បាទ មីង! ខ្ញុំទៅឥឡូវហើយ

អ្នកកំលោះលប់លាងខ្លួនប្រញិបប្រញាប់ ចូលតុបាយដែលមានណាត្រីអង្គុយរង់ចាំជាស្រេច នរៈសង្ហាងើបមុខសំឡឹងនាងក្រមុំ

-មុំ (ឈ្មោះហៅក្រៅរបស់ណាត្រី) មិនរង់ចាំលោកពូសិនទេហ្អី?

ស្រស់ស្រីញញឹមគ្រវីក្បាល

-លោកប៉ាចេញក្រៅដូច្នេះ ច្បាស់ជាបាយហាងហើយ យើងមិនបាច់ចាំគាត់ទេ!

ណាត្រីមានចំណូលចិត្តនឹងរូបរាងដ៏សង្ហា ព្រមទាំងចរិតរាបសាររបស់បងប្រុសជីដូនមួយនាងដែរ ព្រោះ២ឆ្នាំកន្លងមកនេះពួកគេរស់នៅជិតស្និតក្បែរគ្នាព្រឹកល្ងាច។

យុត្តិការៀននៅមហាវិទ្យាល័យអក្សរសាស្ត្រ គេស្រឡាញ់មុខវិជ្ជាសា-ស្ត្រាចារ្យ ដែលអាចអប់រំបណ្តុះបណ្តាលកូនខ្មែរជំនាន់ក្រោយបន្តទៅទៀត អ្នកកំលោះមិនចូលចិត្តការងារណាដែលអ្នកយល់ថាកិបកេងលើកំលាំងញើសឈាមអ្នកដទៃនោះឡើយ ហើយយុត្តិកាត្រូវប្រលងចេញឆ្នាំនេះផង។ អ្នកកំលោះដួសបាយញុំាបណ្តើរ

-អ្នកណាមកជួបលោកពូអំបាញ់មិញ?

មាណវីសើចតិចៗ

-ថៅកែតូចរបស់លោកប៉ា! មិនដែលមកដល់ផ្ទះយើងទេមុនៗ ឥឡូវឮថាត្រូវបើកសណ្ឋាគារនៅមាត់ទន្លេ លោកប៉ាប្រាប់ខ្ញុំយប់មិញថាចង់ឱយខ្ញុំចូលធ្វើការទីនោះដែរ កុំឱ្យខ្ញុំទំនេរពេក ព្រោះខ្ញុំមិនចង់រៀនបន្តទៅមហាវិទ្យាល័យទៀតទេបង ខ្ញុំចង់ចេញធ្វើការស្វែងរកបទពិសោធន៏ជាង។

យុត្តិកាលួចមើលមុខនាងក្រមុំបន្តិច

-បើមុំក៏ចូលចិត្ត ហើយមានលោកពូនៅធ្វើការជាមួយស្រាប់ នោះក៏ល្អម្យ៉ាងដែរ!

ណាត្រីទ្រឹងមើលមុខយុត្តិកា

-មើលទៅទឹកមុខបង ដូចជាមិនសូវសប្បាយចិត្តនឹងខ្ញុំបានចូលធ្វើការសោះ?

អ្នកកំលោះញញឹមស្ងួត

-បើជាបំណងរបស់លោកពូ បងមានស្អីនិយាយនោះ គ្រាន់តែបងគិតថា ស្រីៗធ្វើការនៅសណ្ឋាគារដូចជាមិនសូវល្អសោះ ព្រោះទីនោះមានប្រុសៗចេញចូលច្រើន

នាងក្រមុំអស់សំណើច

-ស្លាប់ហើយបង...ប៉ានៅទីនោះទាំងមូលអ្នកណាហ៊ានប៉ះពាល់ខ្ញុំនោះ? ខ្ញុំទៅធ្វើការជាលេខាផ្ទាល់របស់លោកជីន មិនមែនអ្នកបំរើរៀបចំបន្ទប់ទេណា៎!

អ្នកកំលោះរអ៊ូក្នុងចិត្ត(អានឹងហើយដែលបងបារម្ភនោះ) តែខាងក្រៅយុត្តិកាខំប្រឹងសើចស្រាល

-ខ្ញុំសុំជួយអបអរអ្នកនាងលេខា!

ណាត្រីសំឡក់យុត្តិកាទាំងខ្នាញ់

-ស្អីក៏ក្បាច់ក្បូរម្ល៉េះបង?

ភ្នែកទង្គិចគ្នា បង្កប់នូវមនោសញ្ចេតនាសែនជ្រៅ ទោះជាពួកគេមិនដែលនិយាយពាក្យថាស្រឡាញ់ តែពន្លឺភ្នែកមានន័យជាងពាក្យសារភាពរាប់រយផង។ ភ្នែកកំលោះមុតថ្លាពេក នាងក្រមុំក៏គេចមុខចេញបន្លប់ភាពអៀនប្រៀនណាមួយពេលនោះមីងនាតចូលមកថែមបាយឱយផង។

---

ខ្យល់ជំនោរដងទន្លេ ពិតជាត្រជាក់ជ្រួតជ្រាបពេញអារម្មណ៍ សំឡឹងទៅភ្នំខៀវស្រងាត់ជាប់ជើងមេឃ ផ្ទាំងថ្មឈរទ្រឹងសំឡឹងរលកទឹកបក់បោកប្រដេញរមេញនឹងសត្វបក្សាបក្សីដែលហោះហើរឆ្វែលឆ្វាត់ពេញលំហមេឃ នៅលើយ៉លំហៃនៃសណ្ឋាគារថ្មី ជីនកំពុងឈរក្បែរណាត្រីសំឡឹងមើលគំរោងរៀបចំដែលនាងបានជ្រើសរើសមកបង្ហាញគេដោយទឹកមុខរីករាយ

-អ្នកនាងពូកែរើសមែន! រនាំងបង្អួចទ្វារពណ៌ខ្ចីដូច្នេះ ស៊ីនឹងគ្រឿងសង្ហារឹម ដែលយើងកុម្ម៉ង់មកនោះហើយ ខ្ញុំត្រេកអរណាស់ ដែលបានលេខាឆ្លាតដូចអ្នកនាងមកធ្វើការជាមួយ!

ឆោមស្រស់សើចញញឹម១

-មិនហ៊ានទទួលពាក្យសរសើរដល់ម្លឹងទេលោក ព្រោះនេះជាការងារដកពិសោធន៏ដំបូងរបស់ខ្ញុំ

ជីនញញឹមដាក់នាងដោយក្តីពេញចិត្ត

-តែអ្នកនាងឆ្លាតដូចឪពុកអញ្ចឹង បើសិនជាលោកពូមិនពូកែទេ ធ្វើម៉េចបានលោកប៉ាខ្ញុំទុកចិត្តនោះ! អ្នកនាងហត់នឿយប៉ុន្មានថ្ងៃហើយ ខ្ញុំចង់អញ្ជើញទៅញ៉ាំបាយមួយពេល ចាត់ទុកជាការតបស្នងណា៎!

ណាត្រីសំឡឹងមុខជីន

-ខ្ញុំជាអ្នកធ្វើការងារឱយលោក ធ្វើម៉េចនឹងហ៊ានទាមទារការតបស្នងបែបនេះ?

អ្នកកំលោះរូបស្រស់ល្ងួកដៃក្នុងហោប៉ៅញញឹមស្រាល

-ខ្ញុំថាលេងទេ! គឺខ្ញុំមានចិត្តចង់នាំអ្នកនាងទៅញ៉ាំអីជាមួយគ្នាបានម្តងហើយមិនប្រើសិទ្ធិជាប្រធាន និង លេខាឡើយ ហើយក៏មិនចង់ឱយណាត្រីហៅខ្ញុំថាលោកដែរ។ យើងគួរតែរាប់អានគ្នាបានស្និទ្ធស្នាលជាងនេះ ព្រោះលោកពូជាជំនិតរបស់លោកប៉ាខ្ញុំ ៤ . ៥ ឆ្នាំមកហើយ ល្មមអាចឱ្យយើងរាប់អានគ្នាដូច

សាច់ញាត្តិបាន កុំតែខ្ញុំជាប់ទៅរៀននៅបរទេស កុំអីខ្ញុំបានស្គាល់អ្នកនាងយូរហើយ! ហើយខ្ញុំក៏មិនចាំបាច់ស្ដាយពេលវេលាដូចជាពេលនេះដែរ!

មាណរីងើបមើលមុខជីនភាំងបន្ដិចគេស្រស់សង្ហាមិនចាញ់យុត្តិកាតំរេះក៏មិនអន់ជាង ឯទ្រព្យក៏លើសលប់ថែមទាំងពូកែប្រើពាក្យផ្អែមល្ហែម យល់ចិត្តស្រី មិននឹងធឹងពេកហើយត្រង់ៗពេកដូចយុត្តិកាទេ។

ប៉ុន្មានថ្ងៃនេះស្រីស្រស់នៅធ្វើការជាមួយគេជាប់ ក៏ដូចជាទទួលអារម្មណ៍ថា ពីមុនមកនាងបានឃើញនឹងជិតស្និទ្ធតែជាមួយយុត្តិកាម្នាក់ ទើបមិនដឹងថាប្រុសដែលមានលក្ខណៈពេញលេញជាងយុត្តិកាមិនអត់ទេ! ណាត្រីជានារីរហ័សរហួន ទាន់សម័យ...គំនិតរបស់នាងគួចត្របាញ់ខ្ពស់ សំឡឹងឃើញអ្វីដែលរីកលូតលាស់ទៅមុខ មិនធម្មតាឡើយ មាណរីញញឹមស្រាល

-បើសិនជាសមានចិត្តរបស់លោក ខ្ញុំទទួលចុះ!

-អេ! លោកទៀតហើយ...

ណាត្រីសើចទ្រង់អៀន

-ភ្លាមៗ ខ្ញុំទម្លាប់មាត់មិនបានទេលោក...

-បានៗ ខ្ញុំរង់ចាំដល់ពេលអ្នកនាងទម្លាប់បានទៅចុះ

កំលោះក្រមុំនាំគ្នាចុះសំដៅឡាន រួចនាំគ្នាទៅញុំាអាហារនៅភោជនីយដ្ឋានព្រែកលាបព្រោះទីនោះល្បីមានបុកល្ហុងឆ្ងាញ់ បង្គាស្រស់ៗ ល្បីជាងគេនោះគឺ ទឹកជ្រលក់ជូអែម។

នៅក្នុងភោជនីយដ្ឋានជីន និង ណាត្រីអង្គុយទល់មុខគ្នា ជីនចាប់សាច់ដាក់ចានឱ្យនាងដោយយកចិត្តទុកដាក់។ ខណៈនោះម៉ារីចូលមករកញុំាអាហារនៅទីនោះដែរ ព្រោះនេះជាហាង ដែលនាងចូលចិត្តមកជាប្រចាំនៅពេលថ្ងៃសៅរ៍!។ ក្រឡេកឃើញរ៉ាជីនកំពុងរួមតុជាមួយស្រីម្នាក់ដ៏ស្រស់ស្អាត នាងក្រមុំភ្ញាក់ព្រើត ចូលទៅបន្លំកំបាំងជាមួយតុ ដែលមានគ្នាច្រើនកុំឱយជីនឃើញនាង ទោះម៉ារីជានារីទន់ភ្លន់រាបសារមិនដែលហ៊ានដើរលេងរហេតរហូតជាមួយជីនតែក្នុងចិត្តស្រីគោរពទុកដាក់គេជាគូអនាគត ហើយក៏មិនចង់ឃើញគេមានចិត្តមិនស្មោះត្រង់ចំពោះនាងដែរ។ ធីតាអង្គុយផឹកទឹកក្រូចច្របាច់ ខំប្រឹងលបស្ដាប់ការសន្ទនារបស់ជីនដោយទឹកមុខស្ងួតស្ងប់ ណាត្រីនិយាយមួយៗព្រមទាំងសំឡឹងជីនយ៉ាងមុតផង

-ខ្ញុំឮលោកប៉ានិយាយថាលោកជិតរៀបការហើយ! ទើបខ្ញុំមិនចង់ធ្វើអ្វីមួយក្នុងលក្ខណៈមិនសមរម្យសំរាប់ភ្នែកអ្នកផង!

ជីនដកដង្ហើមធំ

-ខ្ញុំក៏មានរឿងខ្លះចង់បញ្ជាក់ឱយណាត្រីបានដឹងដែរព្រោះបើបៀមទុកក្នុងចិត្តម្នាក់ឯង វាធុញថប់ខ្លាំងណាស់ ណាត្រីដឹងទេ? រូបខ្ញុំនេះប្រៀបដូចអ្នកកាត់ខោអាវ ពេលជាងដេររួចហើយ ទោះដឹងថាពាក់មិនសម ក៏ត្រូវទទួលយកហើយវាជាការពិបាកខ្លាំងណាស់ ក្នុងការដែលយើងត្រូវបង្ខំចិត្តធ្វើអ្វីដែលយើងគ្មានចំណូលចិត្តនឹងធ្វើទាល់តែសោះនោះ!

ម៉ារីធ្លាក់ទឹកមុខមួយរំពេច មុខនាងស្លេកស្លាំងអស់ ព្រោះសំរាប់ស្ត្រីវាជារឿងអាម៉ាសបំផុតពេលដែលដឹងថាគូដណ្ដឹងមិនពេញចិត្តរៀបការជាមួយខ្លួន

ហើយបន្ទុះបង្អាប់មុខស្រីផ្សេងដូច្នេះ ណាត្រីបន្ទរដង្ហើមធំ

-ខ្ញុំមិនចូលចិត្តមានឈ្មោះជាមនុស្សទីពាសំរាប់អ្នកណាទេ ទោះចង់ រឺមិនចង់លោកជិតរៀបការហើយ ខ្ញុំសុំឱយការស្គាល់គ្នារបស់យើងនៅត្រឹមតែជាអ្នកធ្វើការជាមួយគ្នារហូតទៅ មិនចង់រាប់អានជាមួយលោកជិតស្និតជាងនេះទេ ហើយការរួមតុអាហារសំរាប់យើងក៏សុំឱយមានតែម្តងនេះបានហើយ!

ជីនមុខស្រងូតលើកទឹកដោះគោឆៅផឹកយឺតៗ ភ្នែកសំឡឹងនាងក្រមុំយ៉ាងមុត

-ខ្ញុំគ្រាន់តែចង់ឱយណាត្រីដឹងថា ខ្ញុំមិនបានរៀបការដោយពេញចិត្តនោះទេ... ហើយ... បើ... បើខ្ញុំពេញចិត្តវិញនោះ... គឺស្រីមានអត្តចរិតរួសរាយរហ័សរហួន ហ៊ាននិយាយហ៊ានថាដូចអ្នកនាងទៅវិញ!

មាណវីងើបមុខឡើងយ៉ាងរហ័សសំឡឹងជីន ភ្នែករបស់គេបញ្ជាក់ប្រាប់យ៉ាងច្បាស់ថាគេចាប់អារម្មណ៍ចំពោះនាង តែគេមិនមែនជាប្រុសទំនេរឯណា? នាងក្រមុំញញឹមស្ងួត

-ខ្ញុំគ្រាន់តែអាចទទួលដឹង! តែបើទទួលឱយលើសពីនេះទៀតមិនបានទេ!

-ប៉ុណ្ណឹងក៏ខ្ញុំពេញចិត្តណាស់ទៅហើយ ព្រោះខ្ញុំបាននិយាយអ្វីដែលខ្ញុំចង់និយាយរួចអស់ហើយ!

ម៉ារីគេចចេញពីទីនេះយ៉ាងលឿន ក្នុងចិត្តអួលណែនថាមិនត្រូវ ។ ជីនជូនណាត្រីត្រឡប់ទៅផ្ទះតែម្តង ។ ចំណែកម៉ារី នាងទៅធ្វើការបន្តតែមុខមិនរីក

សោះ ព្រោះអារម្មណ៍ស្រីវិលវល់តែនឹងសំដីជីន ពេញក្នុងត្រចៀក នាងក្រមុំហាក់ដូចជាឈឺក្បាល ក៏សុំច្បាប់កន្លែងធ្វើការមួយល្ងាច ចេញទៅផ្ទះតែម្តង ។ ម៉ារីស្លៀកពាក់ខោអាវកំប្លែនៅផ្ទះ នាងដើរតាមទ្រើងផ្កាអគីដេយឺតៗទៅឈរផ្អែកដើមជម្ពូ អោបដៃសញ្ជឹងគិតទៅឆ្ងាយ ទឹកមុខក្រៀមក្រំ ។ នាងចេះតែដណ្តឹងសួរខ្លួរឯងថា តើគួររៀបការនឹងជីនឬទេ?

លោកប៉ា ហាក់ដូចជាមានជំនឿមុតមាំណាស់ ទៅលើកូនប្រុសមិត្តភ័ក្តិរបស់លោក! តើលោកប៉ាដឹងអីទេ? ថាគេមិនបានពេញចិត្តនឹងកូនស្រីរបស់ខ្លួននោះ?លោកមឿនដើរចុះពីលើផ្ទះមករកកូនស្រី ឃើញមុខនាងមិនស្រស់ លោកសួរកូនទាំងឆ្ងល់

-រឺមិនស្រួលខ្លួនឬកូន?

ម៉ារីខំញញឹមបន្លប់

-ចាំ ឈឺក្បាលបន្តិចបន្តួច តែកូនលេបថ្នាំរួចហើយ

លោកមឿនងក់ក្បាលតិចៗ

-អ៊ុ មួយរយៈនេះ ដូចជាមិនឃើញជីនគេមកលេងផ្ទះយើង មែនទេកូន?

មាណវីតបតិចៗ

-ប្រហែលជាគាត់ជាប់រវល់ រឿងបើកសណ្ឋាគារថ្មីទេដឹងលោកប៉ា?

-អឺ! ទោះយ៉ាងណា ជិតរៀបការទៅហើយ គេគួរតែឈ្លៀតមកអើតពិគ្រោះគ្នាខ្លះ! ទាំងឪពុកទាំងកូនស្រាប់តែបាត់ឈឹងទាំងអស់គ្នាតែម្តង!

ម៉ារី ងើបមុខឃឹតសំឡឹងឪពុក

-ឬមួយគេមិនពេញចិត្តកូនស្រីប៉ាទេដឹង? កូនថាប្រហែលជាគេធ្វើតាមតែបំណងឪពុក មិនមែនដោយចិត្តគេចង់... ហើយកូនក៏មិនចង់រៀបការរបៀបនេះដែរប៉ា!

លោកមឿនបើកភ្នែកធំៗ

-ម៉េចក៏កូនយល់ដូច្នេះ? កន្លងមកប៉ាឃើញជីន គេមិនដែលបង្ហាញឬកពារមិនពេញចិត្តនឹងកូននោះទេ!

-ប្រហែលជាគេទើបតែរកឃើញអ្នកដែលគេពេញចិត្តទេដឹង បានជាមួយរយៈនេះទើបតែប្លែក!

លោកមឿនក្រវីក្បាលទ្រង់ហួសចិត្ត

-កូននិយាយដូចជាច្បាស់ពេកហើយ គ្រួសារអ្នកមានពូជពង្សវង្ស-ត្រកូលដូចយើងមិនមែនចង់ភ្ជាប់ពាក្យឬផ្ដាច់ពាក្យស្រេចនឹងចិត្តនោះទេ រឿងរៀបការពួកកូនដឹងឮពេញក្រុងទៅហើយ ទាំងកិត្តិយស និង ការទទួលខុសត្រូវគឺទាំងសងខាង មិនអាចប្រែក្រឡាស់ងាយៗទេ!

នាងក្រមុំដកដង្ហើមធំ ពាក្យថាកិត្តិយសមួយម៉ាត់នេះ បង្ខំឱយមនុស្សពីរនាក់ត្រូវតែបង្ខំចិត្តរស់ជាមួយគ្នា ដោយគ្មានសេចក្ដីស្រឡាញ់ដូច្នេះឬ? តែនាងជាកូនស្រីប្រកបដោយគន្លងធម៌ គោរពតាមការទុកដាក់របស់ឪពុកម្ដាយ មិនចង់ប្រកែកប្រណាំងវែកញែកអ្វីទៀតទេ មានតែទ្រាំតាមដំណើររឿងទៅចុះ។

◆ ◆ ◆ ❖ ◆ ◆ ◆

## ~២~

## ជើងមេឃប្រែពណ៌

ថ្ងៃអាទិត្យនេះ លោកជេន និង លោកមឿនណាត់ជួបគ្នា គិតគូររឿងរៀបការកូន។ជីនអង្គុយក្បែរឪពុកមុខស្មើ ភ្នែកសំឡឹងទៅឆ្ងាយហាក់ដូចជា មិនយកចិត្តទុកដាក់និងការសន្ទនារបស់ឪពុកទេ។ លោកជេនសើចស្រួលណាស់ ជាមួយលោកមឿន ព្រោះម៉ារីជាកូនប្រសារដែលលោកពេញចិត្ត

លោកសានក៏មកជួបជាមួយលោកជេនដែរ ព្រោះកិច្ចការរៀបចំម្ហូបអាហារសំរាប់ពិធីមង្គលការជីន និង ម៉ារី លោកប្រគល់ឱយលោកសានទទួលចាត់ចែង។ ចាស់ៗកំពុងជជែកគ្នារឿងសំបុត្រអញ្ជើញភ្ញៀវ ស្រាប់តែពូសាយសូហ្វ័រឡាន របស់លោកមឿនដែលជូនម៉ារីទៅផ្សារទិញឥវ៉ាន់ រត់ចូលមកទាំងត្រហេបត្រហប ទឹកមុខភិតភ័យខ្លាំងណាស់!

-លោកប្រុសៗ អ្នកនាងត្រូវគេចាប់ខ្លួនបាត់ហើយ!

គ្រប់គ្នាស្ទុះងើបឈរស្រឡាំងកាំង ស្លុតស្លុងអារម្មណ៍រៀងខ្លួន លោកមឿនស្លន់ស្លោជាងគេ ស្ទុះមកអង្រួនដៃសាយញាប់រន្ថើន

-ម៉េចក៏ទៅជាអញ្ចឹង? សាយឯងបានឃើញមុខពួកវាទេ? យើងទៅប្ដឹងប៉ូលីសឱយទាន់ពេលភ្លាមទៅ

-វាជិះឡានមកស្ទាក់ផ្លូវខ្ញុំត្រង់ផ្លូវស្ងាត់ វាមានកាំភ្លើងភ្ជង់អ្នកនាងជាប់ ខ្ញុំខ្លាចវាបាញ់អ្នកនាងទើបមិនហ៊ានស្រែក វាដេញខ្ញុំមិនឱយតាមវាទេ តែខ្ញុំលបតាមវាមិនឱយវាដឹង ស្រាប់តែខ្ញុំឃើញវាមានគ្នាម្នាក់ទៀតជិះម៉ូតូតាមក្រោយគ្នាជាប់ ហើយទៅជួបគ្នានៅចំការមួយទៀតផង ម្នាក់នោះខ្ញុំស្គាល់ច្បាស់គឺក្មួយលោកសានឈ្មោះយុត្តិកានោះ!

លោកសានបើកភ្នែកក្រឡង់មុខខ្មៅអែ

-ខ្ញុំមិនបានដឹងទេលោកថៅកែ វាមកសុំស្នាក់នៅជាមួយខ្ញុំ ដើម្បីរៀនសូត្រ ខ្ញុំក៏ទទួលព្រោះគិតថាជាក្មួយប្រពន្ធខ្ញុំ មិននឹកស្មានសោះថាវា ជាមនុស្សពាលដូច្នេះ សុំលោកប្ដឹងប៉ូលីសចាប់វាធ្វើទោសតាមច្បាប់ចុះ ខ្ញុំមិនទទួលស្គាល់មនុស្សអាក្រក់ដូច្នេះឡើយ!

លោកមឿន ចេញទៅជាមួយសាយយ៉ាងប្រញាប់ប្រញាល់ទាំងក្ដីព្រួយបារម្ភ ជីនគិតតែឈរភាំង ឯលោកសានឈ្ងោកមុខជ្រប់ ព្រោះអាម៉ាសមុខនឹងក្មួយប្រុសទៅរួមដៃជាមួយជនពាល លោកជេនងាកមកសួរកូន

-នែ! ម៉េចក៏កូនមិនឆាប់តាមទៅជួយរកម៉ារីភ្លាមទៅ?

វ៉ាជីនធ្វើមុខធុញទ្រាន់ឆ្លើយទាំងមុខមិនសូវស្រួល

-បាទ!

រួចគេដើរចេញរឹងទៅ ។លោកជេនដើរចុះដើរឡើង នៅចាំស្ដាប់ដំណឹងទាំងចិត្តអន្ទះសារ។

នៅក្នុងចំការស្ងាត់ ផ្លូវទៅព្រែកលាប កំលោះជើងអ្នកលេងដៃដល់កំពុងឈរព្រៀង ភ្ជង់កាំភ្លើងចំសៀតផ្កាម៉ារី ដៃនាងក្រមុំជាប់ចំណងក្រញ៉ង់នៅក្នុងឡាន ពុទ្ធីជាឈ្មោះបុរសអ្នកលេងនោះ គេទើបតែមានអាយុ ២៤ , ២៥ឆ្នាំប៉ុណ្ណោះ រូបរាងស្អាតសង្ហាដូចជាតួកុនខូវប៊យ បបូរមាត់ញញឹមជាប់ ពោរពេញដោយសំរស់ស្នេហ៍ មិនសមទាល់តែសោះ ថាបុរសរូបសង្ហាសមសួនយ៉ាងនេះបែរជាតាំងខ្លួនធ្វើជនពាលទៅវិញ ដៃគេភ្ជង់សៀតផ្កាម៉ារីដោយអូសនាងចេញពីក្នុងឡានបណ្ដើរ ឯភ្នែកសំឡឹងទៅយុត្តិកាដែលកំពុងឈរក្ដាប់ដៃទល់មុខគេនោះ រួចគេបន្លឺទាំងមុខញញឹមស្ងួត

-ឯងចង់ឱយនាងស្លាប់មែនទេ! បានជាហ៊ានតាមមកដល់ទីនេះ?

ម៉ារីសំឡឹងមកយុត្តិការទាំងភិតភ័យ គេទាំងពីរធ្លាប់ស្គាល់គ្នា ពេលមួយនោះយុត្តិកាគ្រុនក្ដៅ ហើយបានទៅសំរាកព្យាបាលនៅមន្ទីពេទ្យ ដែលម៉ារីធ្វើការ តែអ្នកកំលោះរូបស្រស់ មិនបានដឹងថានាងជាគូដណ្ដឹងរបស់ជីនទេ។

យុត្តិកាសំឡឹងទៅក្នុងកាំភ្លើងរបស់ពុទ្ធីទាំរន្ធត់ក្នុងចិត្ត

-ខ្ញុំសុំអង្វរឯង! អាចដោះលែងនាងបានទេ? ឯងចង់បានអ្វី អាចដោះស្រាយគ្នាបានទេតើ អ្នកនាងពេទ្យជាស្រីស្លូតបូតណាស់ មិនគួរមករងការប្រមាថដូច្នេះឡើយ ខ្ញុំមិនហ៊ានប្ដឹងខំតាមមកអង្វរឯង ព្រោះចង់ឱយនាងរស់មិនចង់ឱយនាងស្លាប់ទេ!

ពុទ្ធីកំលោះអ្នកលេង ជ្រួញចិញ្ចើមបន្តិច

-យើងធ្វើការព្រោះចង់បានប្រាក់ មានគេជួលយើងឱយចាប់នាងមក រឿងអីយើងត្រូវដោះលែងនាងទៅវិញងាយៗនោះ? យកលុយឯងឈប់តាមរំខានយើងទៅ! ធានាថាស្អែកយើងនឹងលែងនាងទៅវិញហើយ!

ម៉ារីមុខស្លាំង ដោយក្ដីភ័យខ្លាចគេយកនាងទៅរំលោភបំពាន យុត្តិកាឈាន១ជំហ៊ានទៅមុខ

-បើឯងចង់បានប្រាក់ ឪពុកនាងក៏អាចឱយឯងបានដែរ ឱយតែឯងដោះលែងនាងទៅ!

ពុទ្ធីក្រវីក្បាល

-មិនបានទេ! យើងទទួលលុយពីគេរួចហើយ ទោះយ៉ាងណាក៏ត្រូវទុកនាង១យប់ដែរ! ឯងមិនបាច់និយាយច្រើននាំតែខាតកំលាំងទេ!

យុត្តិកាខាំមាត់វាចាម៉ឺងម៉ាត់

-ខ្ញុំដឹងថាជនដែលតាំងខ្លួនជាអ្នកលេង មិនស្ដាប់ត្រឹមពាក្យអង្វរនោះទេ បើប្រាក់ហើយឯងនៅតែមិនព្រមប្ដូរទៀត ខ្ញុំនៅមានតែទឹកចិត្តជាកូនប្រុសចង់ភ្ជាល់ជាមួយឯង មិនដឹងជាអ្នកលេងម្នាក់ដូចឯង មានសេចក្ដីក្លាហានហ៊ានភ្នាល់ជាមួយខ្ញុំរបៀបជាកូនប្រុសដែរឬទេ?

ពុទ្ធីញញឹមរហូត ប្រៀបដូចរូបគេជាមនុស្សដែលមិនចេះកើតទុក្ខទាល់តែសោះ។ មាត់ញញឹមមែន ឯភ្នែកវិលរហូត បញ្ជាក់នូវភាពប្រុងប្រយ័ត្នរបស់គេ

-ភ្នាល់គ្នា? ភ្នាល់របៀបម៉េចទៅ? ដូចជាសប្បាយម៉្យាងដែរ! តែកុំភ្នាល់វៃតប់ជាមួយយើងអី ព្រោះឯងប្រាកដជាមិនឈ្នះយើងទេ!

យុត្តិកាក្រវីក្បាលតិចៗ

-ខ្ញុំជានិស្សិតម្នាក់ ធ្វើម៉េចនិយាយជាមួយឯងពីរឿងវៃតប់បាន? ខ្ញុំចង់ភ្នាល់ពីសេចក្ដីក្លាហានរបស់កូនប្រុស គឺចាក់ខ្លួនឯងនឹងកាំបិត អ្នកណាហ៊ានចាក់ច្រើនកាំបិតជាង អ្នកនោះឈ្នះ! បើខ្ញុំឈ្នះឯង! ឯងត្រូវដោះលែងអ្នកនាងម៉ារីឥឡូវនេះ! បើឯងទុកនាងដល់១យប់នោះ! កិត្តិយសនាងជាងស្រីគ្មានសេសសល់អ្វីទៀតទេ!

ពុទ្ធីធ្វើភ្នែកស្លឹ ព្រោះស្មានមិនដល់ថាយុត្តិកាចេះនឹកឃើញវិធីឈឺសាច់បែបនេះដែលធ្វើឱយ ពុទ្ធីស្ញើចយុត្តិកានោះគឺ ទឹកចិត្តអង់អាចរបស់យុត្តិកាដែលហ៊ានលះបង់ដើម្បីអ្នកដទៃម្នាក់ដែលមិនមែនជាសាច់ញាត្តិនិងគេសោះ បើមើលសភាពខាងក្រៅទៅ គេគ្រាន់តែជានិស្សិតម្នាក់ដ៏ទន់ខ្សោយមិនគួរចិត្តមុតដល់ម្ល៉ឹងទេ!

-យើងទើបនឹងបានជួបមនុស្សដូចឯងនេះជាលើកដំបូងបង្អស់ ក្នុងឆាកជីវិតហក់លោតរបស់យើង! ហើយវាជាល្បែងភ្នាល់ដ៏ចំឡែកអស្ចារ្យទៀតផង!

យុត្តិកាបើកភ្នែកធំៗ

-ឯងមិនហ៊ានមែនទេ!

ពុទ្ធីសើចស្ងួត

-ពេលនេះនាងនៅក្នុងដៃយើង! យើងជាអ្នកឈ្នះស្រាប់ទៅហើយ បើគិតឱយដល់ទៅ យើងមិនចាំបាច់ភ្នាល់នឹងឯងទេ! តែយើងក៏ចង់ឃើញសេចក្ដី

ក្លាហានរបស់ឯងដែរ! ចាត់ការមុនទៅអ្នកក្លាហាន!

និយាយចប់ពុទ្ធីហួតកូនកាំបិតស្នៀតពីកស្បែកជើងគេបោះទៅឱ្យយុត្តិកា ម៉ារីខំរើកញ្ច្រោលក្នុងដៃពុទ្ធីទាំងតក់ស្លុត

-កុំធ្វើអញ្ចឹងយុត្តិកា...កុំអីលោកបងស្មានថាគេកាន់ពាក្យសច្ចៈជាមួយបងឬ? បែបនេះបងល្ងង់ពេកហើយ!

-មនុស្សដូចខ្ញុំហ៊ានស៊ីហ៊ានសង បើមិនអញ្ចឹងខ្ញុំមិនចាំបាច់មកភ្នាល់ឆ្កួតៗជាមួយឯងទេ

យុត្តិការអោនរើសកាំបិតឃើតៗ សំឡឹងមុខពុទ្ធីយ៉ាងមុត

-ខ្ញុំក៏យល់ដូច្នេះដែរ! សង្ឃឹមថាខ្ញុំមើលមនុស្សមិនខុសទៅចុះ! រួចគេខាំមាត់លើកកូនកាំបិតបុកចំកំភួនដៃឆ្វេងខ្លួនឯង ជ្រួក! ឈាមហូរវ៉ារី តក់ពេញដីក្បែរជើងរបស់គេ ម៉ារីស្រែកយ៉ៃនៅក្នុងឡាន

-យុត្តិកា...

អ្នកកំលោះសង្ហា ញ័រខ្លួនចំប្រប់ ញើសហូរជោកថ្ងាស គេចាប់ដងកាំបិតកន្ត្រាក់ចេញពីកំភួនដៃ ធ្វើឱ្យឈាមរិតតែហូរ មាណពស្រវាកន្សែងដៃពីហោប៉ៅខោមកខ្ទប់មុខរបួស ខំឈរជ្រែងទប់ជំហរ រួចបោះកូនកាំបិតទៅឱ្យពុទ្ធីវិញ វាចាទាំងមុខស្លាំង

-ដល់ពេលឯងហើយ!

ពុទ្ធីអោនរើសកាំបិតមកជូតឈាមស្អាតស៊កទុកវិញ និយាយទាំងញាក់ស្មាផង

-គ្រាន់បើមែន! ចាត់ទុកថាខ្ញុំចាញ់ឯងទៅចុះ ព្រោះខ្ញុំមិនចង់ឈឺសាច់ទទេៗឡើយ!

មុខស្លេកស្លាំងរបស់យុត្តិកាប្រែទៅជាមានឈាម និង រីករាយយ៉ាងខ្លាំងស្ទុះទៅមុខទាំងជើងញ័រទទ្រើក ពុទ្ធីបើកទ្វារឡានស្រាយចំណងឱ្យម៉ារីភ្ញាក់កំលោះអ្នកលេងផ្តោតជាប់រង្វង់ភ័ក្ត្រសោភារបស់ស្រស់ស្រី ភ្លឹកអស់បន្តិចដែរ គេសើចតិចៗ

-ស្រស់ណាស់! ដំបូងខ្ញុំមិនបានចាប់ភ្លឹកទេ! អ្នកនាងពិតជាមានតម្លៃល្មមឱ្យគេម្នាក់នោះលះបង់ឈាមស្រស់មែន!

ម៉ារីគេចមុខចេញពីក្រសែភ្នែកពុទ្ធីរួចរត់ចេញពីឡានយ៉ាងលឿន ទៅរកយុត្តិកា នាងគ្មាននិយាយអ្វីទាំងអស់ ស្រវាហូតកន្សែងស្បៃចងសក់របស់នាងមកចាប់ដៃអ្នកកំលោះរុំរបួសឱ្យយ៉ាងរហ័ស ព្រោះនាងជាគ្រូពេទ្យស្រាប់ភ្នែកស្រីសំឡឹងគេទាំងក្តុកក្តួលញាប់ញ័រ របូតស្រក់ទឹកភ្នែកសន្សឹមៗ ដោយមិនដឹងខ្លួន។ ពុទ្ធីជៀងភ្នែកមើលអ្នកទាំងពីរបន្តិច រួចចូលក្នុងឡានបើកចេញទៅយ៉ាងលឿន នាងក្រមុំសំឡឹងមុខយុត្តិកា

-បងឆាប់ទៅពេទ្យដាក់ថ្នាំសិនទៅ ហើយយើងគួរប្តឹងប៉ូលីសចាប់ខ្លួនគេដែរទេ?

-យើងកុំបង្ករឿងជាមួយគេអី! ខ្ញុំថាបញ្ចប់ត្រឹមនឹងចុះ គេនោះមិនមែនធម្មតាទេ បើគេគ្មានចិត្តជាកូនប្រុស ពេលនេះយើងទាំងពីរក៏មិនបានរួចខ្លួនដែរ!

-អញ្ចឹង ខ្ញុំនាំបងទៅពេទ្យរុំរបួសសិន!

អ្នកទាំងពីរប្រញាប់ចាកចេញពីទីនោះភ្លាម ព្រោះខ្លាចពុទ្ធីកែប្រែចិត្ត ត្រឡប់មកវិញ។

ដាក់ថ្នាំឃាត់ឈាមរុំរបួសនៅមន្ទីរពេទ្យរួចរាល់មាណពសំឡឹងមុខម៉ារី

-អ្នកនាងប្រញាប់ទៅផ្ទះវិញចុះកុំឱ្យមានការជ្រួលច្របល់ទាន់ ចំណែកខ្ញុំអាចទៅផ្ទះខ្លួនឯងបាន!

ខ្លាចឪពុកបារម្ភពីនាងដែរ ទើបម៉ារីសុខចិត្តបែកផ្លូវពីយុត្តិកា ទាំងចិត្តនៅព្រួចបារម្ភដល់សុខភាពរបស់គេខ្លាំងណាស់។

គ្រាន់តែយុត្តិកាចូលដល់ក្នុងផ្ទះភ្លាម លោកសាន និង ណាត្រីបើកភ្នែកធំៗធ្វើមុខក្រញ៉ូវដាក់តែម្តង។ មាណពធ្វើភ្នែកស្លី ព្រោះមិនបានដឹងរឿងពូសាយយល់ច្រលំថាអ្នកជាដៃជើង មនុស្សខូច។ លោកសានចង្អុលមុខយុត្តិកាទាំងខឹងញ័រមាត់ ព្រោះគាត់អង្គុយចាំឱយតែយុត្តិកាលេចមុខមកដល់

-ឯងទើបនឹងមកពីណា? កុហក់យើងថាមកសុំស្នាក់នៅរៀន តែតាមការពិត! មកប្រព្រឹត្តខ្លួនឃក់លោតជាមួយពួកអ្នកលេងថោកទាបទៅវិញ! ឆាប់រៀបខោអាវចេញពីផ្ទះ យើងភ្លាម! កុំឱយប៉ូលីសគេមកអូសក្បាលឯងចេញ ពីផ្ទះនេះទាន់! ព្រោះវាជារឿងអាម៉ាសខ្លាំងណាស់!

យុត្តិកាធ្វើភ្នែកស្លី

-លោកពូ...ខ្ញុំមិនយល់ទេ! តើខ្ញុំមានកំហុសអី?

ណាត្រីងើបឈរយឺតៗសំឡកយុត្តិកាដោយទឹកមុខខកចិត្តខ្លាំងណាស់

-នៅមកធ្វើពីទៀត? ពូសាយគាត់លបតាមពីក្រោយឃើញច្បាស់ទៅហើយ! ថាអ្នកឯងនេះរួមគំនិតជាមួយអាអ្នកលេងម្នាក់នោះ ចាប់ខ្លួនម៉ារីទៅ! លោកអ៊ុំមឿនទៅប្តឹងបាត់ហើយ! ត្រៀមខ្លួនចូលគុកទៅ

អ្នកកំលោះធ្វើភ្នែកស្លី

-ទៅប្តឹងហើយ? ហ៊ឺអ្នកនាងម៉ារី ទីបំផុតខ្ញុំនៅតែមិនអាចជួយការពារកិត្តិយសរបស់អ្នកនាងបានដដែល។ លោកពូ ខ្ញុំមិនបានផ្សំគំនិតជាមួយមនុស្សអាក្រក់ទេ! វាជាការភ័ន្តច្រលំប៉ុណ្ណោះ!

លោកសានខាំមាត់ចង្អុលទ្វារ

-មិនបាច់និយាយស្អីទាំងអស់! ទ្វារបើកចំហស្រាប់! ឯងឆាប់ចេញទៅ! យើងមិនត្រូវការចិញ្ចឹមមនុស្សដូចឯងនេះទេ!

យុត្តិកាល្ហោកមុខលែងហ៊ានតវ៉ាបោះជំហានយឺតៗ ចេញពីផ្ទះធំ ណាត្រីជ្រួញចិញ្ចើមតាមមើលគេពីក្រោយ យុត្តិកាទទួលអារម្មណ៍ឈឺផ្សាក្នុងចិត្តណាស់ ព្រោះអ្នកណាយល់ច្រលំលើអ្នក ក៏មិនអាចឱយអ្នកខកចិត្តស្មើណាត្រីយល់ច្រលំលើអ្នកឡើយ។

មាណពកំពុងរៀបចំខោអាវដាក់កាតាបទាំងទឹកមុខក្រៀមក្រំ អ្នកកំលោះដកដង្ហើមធំគិតដល់អ្នកម្តាយនៅឯចំការ ដែលខំសង្ឃឹមថា អ្នកនឹងបានរៀនច្បាប់គ្រូចេញធ្វើការជាគ្រូបង្រៀនមុខមាត់សមរម្យនឹងគេ ឥឡូវអ្នកមានតែសុំស្នាក់នៅក្នុងវត្តដើម្បីរៀនបន្តប៉ុណ្ណោះ ។ យុត្តិកាយួរកាតាបខោអាវចេញមកដល់មាត់ទ្វាររបងទៅហើយ ឡានលោកមឿនបើកចូលមកដល់ល្មម ព្រោះ

ម៉ារីបានទៅដល់ផ្ទះ ដឹងរឿងឪពុកនាងទៅប្ដឹងឱយគេតាមចាប់យុត្តិកា ទើបពន្យល់រឿងរ៉ាវដល់ឪពុក ហើយនាំគ្នាមកផ្ទះលោកសានភ្លាម ខ្លាចមានការភ័ន្តច្រលំ ។ ដឹងការពិត លោកសានក៏ស្រាយទឹកមុខវិញ ព្រោះលោកមឿនមកសំពះអរគុណទាំងលោកថែមទៀត ដែលចិញ្ចឹមក្មួយបានល្អយ៉ាងនេះ។ ណាត្រីលួចមើលមុខយុត្តិកាតែមិននិយាយអ្វីទេ ម៉ារីស្ទាបដៃរបួសរបស់អ្នកកំលោះដោយយកចិត្តទុកដាក់

-ដៃបងស្ពឹកដែរទេ? ខ្ញុំខ្លាចប៉ះពាល់សរសៃណាំ!

-បាទ! មិនអីទេអ្នកនាង ព្រោះខ្ញុំកំរើកបាន

លោកមឿន ងាកមកអង្អែលក្បាលនាងក្រមុំ

-តោះកូន យើងត្រូវចូលទៅប្រាប់ប៉ូលីសទៀត ហើយត្រូវឆ្លើយបំភ្លឺគេចំណុចខ្លះៗផង!

មុននឹងលាលោកសានត្រឡប់ទៅវិញ ម៉ារីងាកមកផ្ដាំឱយយុត្តិកាទៅលាងរបួសឱយបានទៀងទាត់ តែភ្នែកនាងលួចសំឡឹងណាត្រី ព្រោះនាងទើបបានស្គាល់គ្នានៅពេលនេះថា ស្រីដែលជិនបណ្ដើរថ្ងៃមុននោះជាកូនស្រីលោកសាន ហើយជាបងប្អូនជីដូនមួយ នឹង យុត្តិកាទៀតផង។ នៅមុខប៉ូលីសម៉ារីគ្រាន់តែប្រាប់ថា យុត្តិកាជាអ្នកជួយសង្គ្រោះនាង តែជនដៃដល់នោះនាងចំណាំមុខមិនបានទេ ហើយនាងក៏សុំបញ្ចប់រឿងប្ដឹងផ្ដល់ត្រឹមនោះ។

--------------------------

ថ្ងៃបន្ទាប់គ្នានោះ

នៅក្នុងបន្ទប់សាឡុងផ្ទះលោកមឿន ជិនអង្គុយទល់មុខម៉ារី ទឹកមុខស្មើ

-ម៉ារីគួរតែយល់ បងជាកូនប្រុសម្នាក់ ហើយវាអាម៉ាស់ប៉ុណ្ណា? ដែលគេផ្អើលពេញក្រុងថាគូដណ្ដឹងត្រូវគេចាប់ខ្លួនទៅនោះ? លោកពូប្ដឹងប៉ូលីសថែមទៀត វាខ្ចរខ្ចាយពេញទីក្រុងទៅហើយ អ្នកណាគេជឿថារីត្រឡប់មកវិញដោយល្អបរិសុទ្ធនោះ! ហើយអ្នកអាម៉ាសមុខគឺបង!

នាងក្រមុំធ្លាក់ទឹកមុខ តែនាងខំអត់ធ្មត់

-លោកជិនចង់យ៉ាងម៉េច ក៏និយាយត្រង់ៗមកចុះ ព្រោះខ្ញុំមិនចូលចិត្តលាក់ក្បាលលាក់កន្ទុយទេ!

ជិនសំឡឹងម៉ារីទ្រឹងបន្តិច

-គឺបងសុំជូនពាក្យវិញ! រឿងនេះវាមិនទាក់ទងដល់ចាស់ៗទេ! គឺជាការសំរេចចិត្តរវាងយើងទាំងពីរ! ការរាប់អានរបស់យើងមិនប្រែប្រួលទេ តែបើរឿងរៀបការ...

ស្រស់ស្រីរាដៃ ញញឹមស្ងួត

-ខ្ញុំយល់ហើយ...លោកមិនបាច់និយាយទៀតទេ ខ្ញុំដឹងទៀតថានារីដែលលោកពេញចិត្ត គឺកូនស្រីលោកសាន...

ជិនធ្វើភ្នែកស្លឹ ម៉ារីងើបឈរយឺតៗដោះចិញ្ចៀនពេជ្រភ្ជាប់ពាក្យពីដៃដាក់ទៅលើតុមុខជិន

-ខ្ញុំប្រគល់ចិញ្ចៀននិងសេរីភាពជូនលោកវិញ ព្រោះខ្ញុំក៏មិនចង់រៀបការដោយបង្ខំចិត្តដូច្នេះដែរ ទោះជាគ្មានរឿងរ៉ាវម្សិលមិញក៏លោក នៅតែមានលេសផ្សេងៗទៀតជាបន្ត យើងបញ្ចប់គ្នាដោយវិធីនេះល្អជាង!

រួចនាងដើរចូលក្នុងយ៉ាងលឿន ជីនឈរទ្រឹងមួយសន្ទុះទើបឈោងដៃយកចិញ្ចៀនរួចដើរសំដៅទៅឡានរបស់គេបើកចេញភ្លាម។ គ្រាន់តែដឹងថាជីនទៅសុំផ្ដាច់ពាក្យពីម៉ារីភ្លាម លោកជេនខឹងដាច់ក្បាលដាច់កន្ទុយ ទូរស័ព្ទទៅសុំទោសលោកមឿនយ៉ាងប្រញាប់

-មឿនយើងរាប់អានគ្នាយូរឆ្នាំហើយ! ឯងមិនត្រូវជឿ ហើយធ្វើតាមការយល់ឃើញរបស់អាជីនទេ ខ្ញុំមិនព្រមឱ្យវានិងម៉ារីផ្ដាច់ពាក្យដាច់ខាត ឯងក៏គួរតែគិតដែរណាសំឡាញ់ បើវាទាំងពីរមិនបានរៀបការក្ដីវីត្រូវខូចឈ្មោះកាន់តែខ្លាំង! ខ្ញុំស្រឡាញ់ម៉ារីណាស់ ខ្ញុំមិនចង់ឱ្យកូនយើងផ្ដាច់ពាក្យដូច្នេះសោះ

-ខ្ញុំក៏មិនចង់ដែរ ព្រោះរឿងអ្នកមានកូនស្រីគឺចាំតែខូចខាតប៉ុណ្ណោះ! តែឥឡូវយើងគិតយ៉ាងម៉េច បើកូនយើងវាព្រមព្រៀងគ្នាដូច្នោះទៅហើយ

-ទោះយ៉ាងណាក៏ខ្ញុំមិនព្រមដែរ ស្អែកខ្ញុំនឹងហៅជីនមកនិយាយឱ្យដឹងខុសត្រូវម្ដង ហៅជីនមកនិយាយឱ្យដឹងខុសត្រូវម្ដង ឯងក៏ត្រូវណែនាំម៉ារីដែរ មិនមែនពួកវាចង់ផ្ដាច់ពាក្យក៏ផ្ដាច់វំលងក្បាលចាស់ទុំនោះទេ!

-យើងសំរេចគ្នាអញ្ចឹងចុះ ខ្ញុំក៏មិនចង់យករឿងរ៉ាវ១ថ្ងៃ មកធ្វើឱ្យខូចមិត្តភាពយើងរាប់សិបឆ្នាំមកហើយនោះដែរ!

ជីនទើបនឹងមកពីរៀបចំបង្ហើយកិច្ចការនៅសណ្ឋាគារ គ្រាន់តែចូលដល់ក្នុងផ្ទះលោកជេនបើកភ្នែកធំៗដាក់កូន លោកសានក៏មកជាមួយជីនដែរ លោកជេនសំឡឹងមុខជីនទាំងមិនសប្បាយចិត្ត

-អ្នកណាឱ្យឯងទៅផ្ដាច់ពាក្យជាមួយម៉ារី?

ជីនអង្គុយចុះនៅកៅអីសាឡុងទល់មុខឪពុក។

លោកសានថយទៅអង្គុយឆ្ងាយពីនោះបន្តិច

-លោកប៉ា? ម៉ារីត្រូវជនអាក្រក់ចាប់ខ្លួនទៅ ប៉ះពាល់កិត្តិយសខ្ញុំខ្លាំងណាស់ ប៉ានៅតែចង់បង្ខំឱ្យខ្ញុំទទួលយកនាងជាភរិយាទៀត? ខ្ញុំទ្រាំទ្រនិងក្ដីអាម៉ាសនេះមិនបានទេលោកប៉ា!

លោកជេនទះតុទាំងខឹង

-ទោះជាហេតុផលអ្វីក៏ដោយ ប៉ាមិនឱ្យឯងផ្ដាច់ពាក្យពីម៉ារីទេ ឯងត្រូវយកចិញ្ចៀនភ្ជាប់ពាក្យ ទៅប្រគល់ឱ្យនាងវិញ! បើឯងនៅតែជំនះផ្ដាច់ពាក្យពីម៉ារី ឯងទៅទីណាក៏ទៅចុះ ហើយកុំសង្ឃឹមឱ្យសោះថាបានទទួលអ្វីពីប៉ាសូម្បីតែ១រ!

ជីនធ្លាក់ទឹកមុខមួយរំពេច ឯលោកសានលួចមើលមុខជីនដកដង្ហើមធំមិនចេញស្ដី តែទឹកមុខលោកជេនម៉ឹងម៉ាត់ណាស់ បញ្ជាក់ថាលោកមិននិយាយលេងទេ ជីនធ្វើមុខស្លូតស្ងប់ មិនដឹងថាសំរេចចិត្តបែបណាស្រួល។

រ៉ាជីនកំពុងតប់ប្រមល់ តែម៉ារីឯណោះធូរស្រាលក្នុងចិត្តយ៉ាងរំភើយ រូបស្រីប្រៀបដូចបក្សីរួចផុតពីទ្រុងមានសេរីភាពទាំងកាយទាំងចិត្ត នាងមិនចង់

ជាប់ចំណងគ្រាំគ្រារស់នៅជាមួយអ្នកដែលគេមិនបានស្រឡាញ់នាងនោះទេ។

នៅក្នុងមន្ទីរពេទ្យ នាងក្រមុំសោភាកំពុងប្តូរថ្នាំរបួស និង ផ្លាស់ស្បៃរុំថ្មីឱ្យយុត្តិកា។

អ្នកកំលោះងើបមុខសន្សឹមៗសំឡឹងស្រស់ស្រី

-អ្នកនាងគួរតែឱ្យពេទ្យផ្សេងមករុំឱ្យខ្ញុំក៏បាន! មិនបាច់មកព្យាបាលខ្ញុំផ្ទាល់ដៃទេ គ្រាន់តែហេតុការណ៍កន្លងមកនេះ អាចធ្វើឱ្យលោកជីនមិនសប្បាយចិត្តហើយ! កុំឱ្យមានហេតុមិនល្អផ្សេងៗបន្ថែមទៀតអី

ឆោមស្រស់ញញឹមស្ងួត

-ទោះមានបញ្ហាលើសនេះទៀត ក៏គ្មានអ្វីគួរឱ្យខ្ញុំបារម្ភឬខ្លាចចិត្តគេដែរ! ព្រោះយើងបានសំរេចចិត្តផ្តាច់ពាក្យនឹងគ្នាទៅហើយ!

យុត្តិកាធ្វើភ្នែកស្លឹមើលមុខនាងក្រមុំ ព្រោះអ្នកស្មានមិនដល់ថាជីនធ្វើបែបនេះចំពោះនារីដ៏ស្អាតហើយទន់ភ្លន់ដូច្នេះកើត។ អ្នកកំលោះចាប់អារម្មណ៍ថា ជីនមានចិត្តទៅលើណាត្រី ព្រោះឥឡូវគេព្យាយាមស្និទ្ធស្នាលនិងណាត្រីណាស់ តែបេះដូងជីនផ្លាស់ប្តូររហ័សពេក។ មិនអស់ចិត្តសោះយុត្តិកាស្កាត់ទៅសុំជួបជីននៅសណ្ឋាគារថ្មីរបស់ជីន កំលោះទាំងពីរឈររទល់មុខគ្នា នៅលើជ្រាំងទន្លេក្រោមខ្យល់ជំនោបក់ផាត់ត្រជាក់ល្ហឹមនាពេលរសៀល

យុត្តិកាសំឡឹងជីនហាក់អង្វរក

-លោកប្រុស! ខ្ញុំគ្មានសិទ្ធិអ្វីមកណែនាំលោកទេ! តែខ្ញុំចង់មកសុំអង្វរឱ្យលោកយល់ ព្រោះខ្ញុំជាអ្នកស្ថិតនៅក្នុងហេតុការណ៍នោះ ខ្ញុំហ៊ានធានាថាគ្មានអ្វីប៉ះពាល់តម្លៃអ្នកនាងម៉ារីទេ សុំលោកប្រុសកុំផ្តាច់ពាក្យ ព្រោះតែចិត្តចង្អៀតចង្អល់ធ្វើអី!

ជីន បើកភ្នែកធំៗដាក់យុត្តិកា សំឡឹងមើលមាណពសង្ហាពីលើដល់ក្រោមរបៀបពេបជ្រាយ

-មុននឹងមកនិយាយជាមួយខ្ញុំ មានសំឡឹងខ្លួនឯងច្បាស់ហើយឬនៅ? ថាតើឯងមានតម្លៃល្មមអាចមកណែនាំខ្ញុំបានឬអត់?

-ខ្ញុំដឹង! ថានៈរបស់ខ្ញុំតូចទាបណាស់! តែខ្ញុំមកនេះគឺមកសុំអង្វរលោកប៉ុណ្ណោះ ព្រោះខ្ញុំមិនចង់ឱ្យលោកយល់ខុសចំពោះនារីដ៏ល្អម្នាក់ដូចអ្នកនាងម៉ារី

ជីនជ្រួញចិញ្ចើមលូកដៃជ្រែងហោប៉ៅ

-រឿងរបស់យើងឯងកុំបាច់មកសុំាញុំា អ្វីដែលខ្ញុំធ្វើគឺ សំរេចលើចិត្តខ្ញុំតែម្នាក់គត់! ឯងនេះជាស្អីទៅ? ហ៊ានមកឈឺឆ្អាល? ភ្លើមែន!

ជីនដើរចេញវឹង ទុកឱ្យយុត្តិកានៅឈរភាំងម្នាក់ឯង សំឡឹងស្រទាប់ផ្កាក្រដាស់រុះរោយក្រោមកំលាំងខ្យលបក់បោក នឹកសោកស្តាយដល់ ស្រស់ស្រីម៉ារីដែលបាត់បង់កិត្តិយសផ្ទួនៗ ដែលវាអយុត្តិធមិបំផុតសំរាប់ស្ត្រីគ្រប់លក្ខណៈម្នាក់ដូចនាង។ សំរាប់បេះដូងអ្នកកំលោះក្នុងវេលានេះ ម៉ារីគ្រាន់តែជានារីគួរឱ្យកោតគោរពនិងអាណិតប៉ុណ្ណោះ ព្រោះចិត្តដំបូងរបស់អ្នកមានរូបណាត្រីរួចទៅហើយ។

លោកជេនបង្ខំឱ្យរ៉ាជីនរៀបការជាមួយម៉ារីខែក្រោយនេះ បើគេនៅតែរឹងរូស លោកនឹងកាត់កាល់ជីនចេញពីមតកិរបស់លោកគ្រប់យ៉ាង សូម្បីតែ

សណ្ឋាគារមាត់សមុទ្រដែលជីនកំពុងកាន់កាប់ក៏ដោយ ធ្វើឱ្យម៉ារីក៏ត្រូវវង្វេងការចង្អៀតចង្អល់ក្នុងចិត្តយ៉ាងធ្ងន់ធ្ងរដែរ ។

--------------------------

រាត្រីកាលក្រាលស្បៃងងឹត គ្របភពផែនដី រស្មីដួងតារាខំប្រជែងគ្នារះបំភ្លឺផ្ទៃមេឃដ៏ស្រអាប់នារាត្រីវេនោច ដែលបង្កប់ទៅដោយទុក្ខក្រៀមក្រំ ។ នៅក្នុងសួនច្បារផ្ទះលោកសាន យុត្តិកាកំពុងអង្គុយផ្អែកទោងឈើលើកដៃរបួសដែលមានស្នាមក្រឡៅមកមើល ទឹកមុខសញ្ជឹងទៅឆ្ងាយ ។ ស្រស់ណាត្រីក្នុងសំលៀកបំពាក់ដំណេកមួយកំប្លេ ដើរយឺតៗមកឈរអោបដៃក្រោយខ្នងមាណព

-ស្នាមរបួសនេះជិតជ្រៅក្នុងចិត្តបងហើយមែនទេ? ម៉ារីស្រស់ស្អាតវាបសារទៀតផង សមល្មមនិងទទួលការលះបង់ខ្ពស់បំផុតរបស់បងហើយ តែគួរឱយស្តាយ ព្រោះគេត្រូវរៀបការឆាប់ៗនេះ!

នរៈរូបស្អាតបែរមករក ណាត្រីយ៉ាងរហ័ស

-មុំកុំយល់ច្រលំឱយសោះ អ្វីៗដែលបងធ្វើគឺ ដោយសេចក្តីល្អស្មោះត្រង់ បង់ចាត់ទុកអ្នកនាងរឺដូចជាប្អូនស្រី មិនបានគិតអ្វីផ្សេងទេ... តែ... តែចំពោះអូនវិញ! ពេលដែលមុំយល់ច្រលំមកលើបងនោះ...បងឈឺចិត្តខ្លាំណាស់ព្រោះសូម្បីតែមុំក៏មិនយល់ពីបងដែរ

ណាត្រីយល់ នាងមិនល្ងង់ទេ ថាយុត្តិកាកំពុងបញ្ចាក់ទឹកចិត្តគេប្រាប់នាង នាងចាប់អារម្មណ៍នឹងជីនដែរ តែជីនជិតរៀបការទៅហើយទើបនាងក្រមុំយល់ថាគួរជ្រើសរើសប្រុសដែលមានបេះដូងទំនេរនិងស្មោះត្រង់ដូចយុត្តិកាវិញ ស្រស់ស្រីលូកដៃកាច់ផ្កាណាត្រីក្រពុំ១ទង មកថើបថ្នមៗរួចដាក់ផ្កានោះទៅក្នុងដៃយុត្តិកាទាំងញញឹមស្រាល

-ឥឡូវនេះខ្ញុំយល់ពីចិត្តបងច្បាស់ហើយ ផ្កា១ទងនេះវាជំណាងឈ្មោះរបស់ខ្ញុំ ហើយខ្ញុំប្រគល់ជូនបងជំនួសពាក្យសុំទោស ថ្ងៃក្រោយ ទោះមានអ្វីកើតឡើងក៏មិនអាចធ្វើឱយខ្ញុំយល់ខុសលើបងបានដែរ!

រួចនាងបង្វិលខ្លួនចូលក្នុងផ្ទះវិញយ៉ាងលឿន ទុកឱយយុត្តិកាឈរភាំងលើកផ្កាណាត្រីមកមើលរួចគេញញឹមក្តោបផ្កាថ្នមៗ ដើរចូលទៅក្នុងបន្ទប់របស់គេ បើកសៀវភៅអារម្មណ៍ប្រចាំថ្ងៃ មកសិកផ្កាចូលព្រមទាំងសរសេរកំណាព្យពីរបីឃ្លា បញ្ចាក់នូវភាពរឹងមាំនៃបេះដូងរបស់គេ ដែលពោរពេញទៅដោយក្តីសង្ឃឹមក្នុងគ្រានេះ ។